ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ៧៦៧/០៨-៨-២០១២
**សាលដីកា**
លេខ១៨ក្រVIយ
ចុះថ្ងៃទី២១-៥-២០១៣

**គាចនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បើកសវនាការជាសាធារណ:នៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី១០-៥-២០១៣ដែលមានសមាសភាពដូចតទៅៈ

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជំរះ</u>**

**លោក យុន លាងម៉េង ប្រធាន**

**លោក ញូង ធុល ចៅក្រមប្រឹក្សា**

**លោក យន់ ណារ៉ុង ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក ខ៊ែត សារ៉ាត**

**ក្រឡាបញ្ជី**

**លោកស្រី ប៉េស វីណា**

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ៧៦៧ចុះថ្ងៃទី០៨-៨-២០១២រវាងៈ

**-ជនជាប់ចោទឈ្មោះ**[redacted] **ស្រីម៉ៅ(ដើមបណ្តឹងឧទ្ធរណ៍)**ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរជាងអ៊ុតសក់ កើតនៅសង្កាត់លេខ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃ[redacted]សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted](រ) ប្តីឈ្មោះ[redacted] (លែងលះ) មានកូន៣នាក់ ទោសពីមុនគ្មាន។<u>ឃុំខ្លួនថ្ងៃទី១៥.១១.២០១១។</u>





Scanned with CamScanner

**ត្រូវចោទពីបទ៖ «រំលោភលើសេចក្តីទុកចិត្ត »**ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០-៦-២០១១តាមបញ្ញត្តិមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

**.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] **ហួត(ចុងបណ្តឹងឧទ្ធរណ៍)** ភេទប្រុស អាយុ៧៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ១១៦E0 ផ្លូវលេខ២៩៨ ក្រុម៧ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ឃ្លានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៧-២០១២របស់ឈ្មោះ [redacted] ស្រីមៅ មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៨«ថ»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**__ឯដំណើររឿងមានដូចតទៅ៖__**

កាលថ្ងៃទី២០-៦-២០១១ឈ្មោះ [redacted] ស្រីមៅ បានមកជួលឡានរបស់ជនរងគ្រោះ ឈ្មោះ [redacted] ហួត ១គ្រឿងម៉ាក4RUNNER ពណ៌បៃតងចាស់ សេរី១៩៩៦ពាក់ស្លាកលេខភ្នំពេញ២A.២៧២៧ ក្នុងតំលៃ៩៥០$(បួនរយហាសិបដុល្លាអាមេរិច)ក្នុង១ខែ។ក្រោយពីបានឡានរួចឈ្មោះ [redacted] ស្រីមៅក៏យកឡាននោះទៅបញ្ចាំនៅកាស៊ីណូណាហ្គាវើលយកប្រាក់ចំនួន៥០០០$(បួនពាន់ដុល្លាអាមេរិច)។

**ឃ្លានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ២៨«ថ»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញ សំរេចសេចក្តីដូចតទៅ៖

១.ផ្តន្ទាទោស៖

.ឈ្មោះ [redacted] ស្រីមៅ ហៅ ស្រីមៅ ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ (ដែលមានសារពាខាងលើ)ដាក់ពន្ធនាគារចំនួន០៨ខែ គិតចាប់ពីថ្ងៃឃុំខ្លួនថ្ងៃទី១៥.១១.២០១១ ពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០-៦-២០១១ តាមបញ្ញត្តិមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឲ្យឈ្មោះ [redacted] ស្រីមៅ សងសំណងការខូចខាត និង ជំងឺចិត្តជាប្រាក់សរុបចំនួន៩.០០០$(ប្រាំបួនពាន់ដុល្លាអាមេរិច)ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហួត ការទាមទារលើសពីនេះត្រូវច្រានចោល។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៥.៦.២០១២ចំពោះមុខជនជាប់ចោទ និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិឲ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការសាលាឧទ្ធរណ៍។

**__នាពេលសវនាការ__**

ចៅក្រមអានរបាយការណ៍.

ជនជាប់ចោទឈ្មោះ [redacted] ស្រីមៅ ឆ្លើយថា៖ ខ្លួនអាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរជាង



Scanned with CamScanner

អ៊ុតសក់ កើតនៅសង្កាត់លេខ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ៦៣BE0 ផ្លូវលេខ១៣៣ ក្រុម៧ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោករាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ប្តីឈ្មោះ [redacted] (លែងលះ) មានកូន៣នាក់ ទោសពីមុនគ្មាន។ខ្លួនពិតជាបានយកឡានគេទៅដាក់បញ្ចាំមែន តែម្ចាស់ឡានបានយកឡានមកវិញហើយ។ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍ សុំឲ្យតុលាការសំរេចបន្ធូរបន្ថយប្រាក់សំណងដែលត្រូវសងទៅឲ្យគេ ព្រោះម្ចាស់ឡានគេយកឡានមកវិញហើយ។

តំណាងមហាអយ្យការសន្និដ្ឋានថាៈជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ បានទទួលស្គាល់នូវកំហុសរបស់ខ្លួន ប៉ុន្តែសុំឲ្យសាលាឧទ្ធរណ៍ពិចារណាបន្ធូរបន្ថយប្រាក់សំណងដែលត្រូវសងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី។មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស្រីម៉ៅ ពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០-៦-២០១១តាមបញ្ញត្តិមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។សុំសភាព្រហ្មទណ្ឌសំរេចតាមច្បាប់។

ក្រោយពីបានស្តាប់ចំលើយជនត្រូវចោទ.

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន.

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៧-២០១២របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ ប្តឹង ឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២៨«ថ»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន។

២.ជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ បានទទួលស្គាល់នូវកំហុសរបស់ខ្លួន ប៉ុន្តែសុំឲ្យសាលាឧទ្ធរណ៍ពិចារណាបន្ធូរបន្ថយប្រាក់សំណងដែលត្រូវសងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំណុចនេះពុំមានភស្តុតាងណាដើម្បីឲ្យតុលាការពិចារណាឡើយ។

៣.មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស្រីម៉ៅ ពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០-៦-២០១១តាមបញ្ញត្តិមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

៤.សាលក្រមព្រហ្មទណ្ឌលេខ២៨«ថ»/២៥.៦.២០១២សាលាដំបូងរាជធានីភ្នំពេញសំរេចសេចក្តីមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និង អង្គច្បាប់ហើយ គួរតំកល់ទុកជាបានការ។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**



Scanned with CamScanner

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៧-២០១២របស់ជនជាប់ចោទឈ្មោះ [redacted] ស្រី
ម៉ៅ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២.តំកល់សាលក្រមព្រហ្មទណ្ឌលេខ២៨«ច»/២៥.៦.២០១២សាលាដំបូងរាជធានី
ភ្នំពេញទុកជាបានការដដែល។

៣.បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២១-៥-២០១៣ ចំពោះមុខជន
ជាប់ចោទ និង ចាត់ទុកចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី។

បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួល
បន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់
ដំណែងជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមព្រមត្រូវតាមច្បាប់។**

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ហត្ថលេខា [redacted] [redacted] [redacted] [redacted]

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

**បានឃើញ** សាលាឧទ្ធរណ៍,ថ្ងៃទី ១៦ ខែ ០២ ឆ្នាំ២០១៤

**ប្រធានសាលាឧទ្ធរណ៍** **ក្រឡាបញ្ជី**

[redacted] [redacted]



Scanned with CamScanner